អនាគតថ្មី
សម្លេងខ្មែរនៅបរទេស

# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អធិប្បាយអំពីសូត្រមួយហៅថាកាលាសូត្រនៅក្នុងសុត្តន្តបិដកដែលព្រះពុទ្ធសំដែងមិនឲ្យជឿអាការៈ ១០យ៉ាង

web site: hoksavann.org

ថ្ងៃទី១៧ មីនា ២០០៥

កាលាសូត្រមានសំដែងនៅក្នុងគម្ពីរសុត្តន្តបិដកអង្គុត្តរនិកាយតិកនិបាត ដែលបុរសម្នាក់ឈ្មោះកាលាម:បានចូលទៅសួរព្រះសម្ពុទ្ធដោយសេចក្តីសង្ស័យរបស់ខ្លួន អំពីទ្រឹស្តីនៃតាបសឫស្សី ដែលពោលផ្សេងៗគ្នា ពុំដឹងត្រង់ណាជាសេចក្តីពិត បានទូលសួរព្រះពុទ្ធថា បពិត្រព្រះបរមគ្រូដ៏ចំរើន ! ពួកតាបសឫស្សីនិងព្រាហ្មបានពោលអួតសរសើរអំពីលទ្ធិរបស់ខ្លួន ហើយមើលងាយលទ្ធិអ្នកដទៃទៀត ។ ខ្ញុំព្រះអង្គនៅតែមានសេចក្តីសង្ស័យមិនអស់ក្នុងចិត្ត ពុំដឹងជាពួកតាបសឫស្សីនិងព្រាហ្មទាំងនោះ ណាមួយពោលតាមសច្ចធម៌ ណាមួយពោលកុហកយើងឡើយ ។

លំដាប់នោះ ព្រះអរហន្តសម្ពុទ្ធត្រាស់តបថា ម្នាលកាលាម ពិតមែនហើយដែលអ្នកមានសេចក្តីសង្ស័យក្នុងរឿងដែលគួរសង្ស័យ ។ ដើម្បីរកការពិតឃើញ អ្នកត្រូវពិចារណានិងធ្វើការពិសោធន៍ដោយខ្លួនឯងកុំជឿអាការ:១០យ៉ាងគឺ ៖

១-កុំប្រកាន់ជឿដោយឮដោយស្តាប់តាមគ្នា = គឺពាក្យនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ពាក្យនោះពុំអាចយកជាការពិតបានឡើយព្រោះពាក្យនិយាយតៗគ្នាច្រើនឃ្លៀងឃ្លាត ដូចពាក្យខ្មែរក្អែក១ជាក្អែក១០ ។ អ្នកខ្លះឆ្អែតពត៌មានខុសបីការពិត ។ ដូច្នេះពាក្យនិយាយគ្នានេះ កុំប្រកាន់ជឿថា ជាការពិតត្រូវពិចារណាសិន ។

២- កុំប្រកាន់ជឿដោយឃើញថាជារបស់មានតាំងពីដើមមក = កុំប្រកាន់ជឿដោយសំអាងថា របស់នោះមានតាំងពីដើមមក ។ បានសេចក្តីថា កុំយល់ឬជឿថា របស់ពីដើមនោះសុទ្ធតែជាការពិតមានប្រយោជន៍ តែត្រូវពិចារណាសិន ។

៣- កុំប្រកាន់ជឿដោយទទួលដំណឹងថាយ៉ាងនេះៗ = គ្រប់ដំណឹងទាំងអស់ ដែលបានឮចេញពីជនដែលប្រកបដោយលោភ: ទោស: មោហ: ឬប្រកបដោយអគតិធម៌ យកជាការពិតមិនបានឡើយ ត្រូវពិចារណាជាមុនសិន ។

៤- កុំប្រកាន់ជឿដោយអាងតម្រា = គឺប្រកាន់ជឿដោយសំអាងក្បួនច្បាប់ ព្រោះសៀវភៅក្បួនច្បាប់ទាំងនោះ កើតពីមនុស្សសរសេរ, ពិតឬពុំពិតនៅលើការសិក្សាពិចារណាពិសោធន៍មើល ។ ត្រង់ចំណុចនេះព្រះពុទ្ធបានប្រកាសបើកសិទ្ធិថា មុននឹងជឿថាជាធម៌របស់តថាគតឬពុំមែនទេ ចូរអ្នកយកធម៌នោះទៅពិចារណាឲ្យយល់ច្បាស់ដោយខ្លួនឯងជាមុនសិន ។

៥- កុំប្រកាន់ជឿដោយនឹកស្មានយកខ្លួនឯង = សេចក្តីសន្និដ្ឋានជាកត្តាវិជ្ជាការត្រិះរិះជាគំនិតធម្មតានូវបញ្ហាជ្រាលជ្រៅមានអាថ៌កំបាំង ពុំអាចរកការពិតឃើញឡើយ ។

៦- កុំប្រកាន់ជឿដោយយកន័យតាមគំរោងការខាងក្រៅ = គឺជឿដោយវិនិច្ឆ័យតាមគម្រោងឬទ្រង់ទ្រាយខាងក្រៅ ពុំបានពិចារណាឲ្យស៊ីជំរៅនូវការពិតខាងក្នុង ។

៧- កុំប្រកាន់ជឿដោយនឹកគិតតាមអាការ: = គឺមិនត្រូវសន្និដ្ឋានតែតាមអាការ:ខាងក្រៅឡើយ ព្រោះភាពស្តែងប្រាកដឡើងខ្លះ ពុំមានការពិតតាមនោះឡើយ ។ ដូចអាការ:បុគ្គលពាលសំដែងអាការ:ខាងក្រៅដូចជាអាចារ្យចេះធម៌ ដើម្បីបោកអ្នកស្រុក ប៉ុន្តែចិត្តគំនិតជាចោរ ។

៨- កុំប្រកាន់ជឿដោយចូលចិត្តថាត្រូវនឹងលទ្ធិរបស់ខ្លួន = លទ្ធិនិងសាសនានីមួយៗ មានលក្ខណ:ផ្សេងៗគ្នា បើដូចគ្នាវិញពិតជាលទ្ធិនិងសាសនាទាំងនោះមានតែមួយពុំមានច្រើនឡើយ ។ យ៉ាងណាមិញ ព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅផ្សេងពីសាសនាទាំងអស់ក្នុងលោក ទាំងការប្រតិបត្តិ ទាំងគោលដៅ ។ ព្រះពុទ្ធសាសនាប្រតិបត្តិតាមមគ្គប្រកនដោយអង្គ៨ ហើយគោលដៅគឺព្រះនិព្វាន ។ ដូច្នេះកុំឲ្យសន្និដ្ឋានថាសាសនាដទៃមានពាក្យប្រៀនប្រដៅដូចពុទ្ធសាសនាឡើយ ។

៩- កុំប្រកាន់ជឿថានិយាយសមគួរនឹងជឿ = កុំជឿដោយស្មានព្រោះមានអ្នកខ្លះ ប្រើសំនួនវោហារបញ្ចុះបញ្ចូលអ្នកស្តាប់ឲ្យជឿពាក្យដើម្បីគោលដៅអ្វីមួយ ។ ដូច្នេះមុននឹងជឿពាក្យណាមួយ ត្រូវពិចារណាជាមុនសិន ។

១០- កុំប្រកាន់ជឿថា អ្នកនេះជាគ្រូរបស់យើង = សូម្បីអ្នកនោះជាគ្រូរបស់ខ្លួនក៏ដោយ ក៏កុំអាលជឿ ត្រូវតែយកពាក្យគ្រូនោះទៅពិចារណាទៀត ព្រោះលើកលែងតែព្រះពុទ្ធចេញ គ្មានអ្នកប្រាជ្ញណាក្នុងលោកដែលចេះអស់គ្មានភ័ន្តច្រឡំឡើយ ។ សូម្បីព្រះពុទ្ធក៏ព្រះអង្គត្រាស់ឲ្យគេយកពាក្យប្រៀនប្រដៅរបស់ព្រះអង្គទៅពិចារណានិងធ្វើការពិសោធន៍ ឲ្យឃើញការពិតមុននឹងជឿពាក្យរបស់ព្រះអង្គដែរ ។

ទីបំផុតព្រះពុទ្ធបានត្រាស់ទៅកាន់កាលាមថា បើអ្នកបានត្រិះរិះពិចារណាយ៉ាងល្អិតល្អន់ បានធ្វើការពិសោធន៍ ហើយយល់ឃើញថាល្អត្រឹមត្រូវ ជាបុណ្យជាកុសល នាំមកនូវសេចក្តីសុខចំរើនដល់អ្នកនិងជនដទៃនោះ អ្នកគប្បីទទួលជឿហើយយកទៅប្រតិបត្តិចុះ ។ បើអ្នកត្រិះរិះពិចារណាទៅឃើញថា ជាគ្រឿងផ្ទុយនឹងបុណ្យកុសលដើម្បីខ្លួននិងអ្នកដទៃនោះ ត្រូវតែលះបង់ចោលឲ្យស្រឡះពីខន្ធសន្តានរបស់អ្នក ។ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដ៏សំខាន់ណាស់ ក្នុងការពន្យល់ពុទ្ធបរិស័ទរបស់ព្រះអង្គឲ្យប្រើបញ្ញាពិចារណាមុននឹងជឿអ្វីមួយ ដែលគ្មានលទ្ធិសាសនាណាប្រៀបប្រដូចបានឡើយ ។ សាសនាដទៃបង្ខំគេឲ្យជឿដោយថាតែតាមគម្ពីរ មិនចាំបាច់ពិចារណាវែកញែករកការពិតឡើយ ។៚